# លក្ខខណ្ឌទូទៅក្នុងការប្រើប្រាស់គណនីមានកាលកំណត់
# ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី

១- គណនីមានកាលកំណត់ គឺជាកិច្ចសន្យារវាងអតិថិជន និងធនាគារ អេស៊ីលីដា ភីអិលស៊ី ស្តីពីការដាក់ប្រាក់បញ្ញើ នៅក្នុងអំឡុងពេលកំណត់មួយជាក់លាក់ ដើម្បីទទួលបានការប្រាក់ខ្ពស់ និងសុវត្ថិភាព ។

២- អតិថិជនអាចដកប្រាក់បញ្ញើបាន ចាប់ពីកាលបរិច្ឆេទបញ្ចប់ នៅក្នុងវិញ្ញាបនបត្រប្រាក់បញ្ញើ នៅតាមបញ្ជរបេឡា ឬតាមរយៈម៉ាស៊ីនអេធីអឹម (ទំហំទឹកប្រាក់បញ្ញើដែលដកអាស្រ័យតាមប្រភេទប័ណ្ណ) ។

៣. ការដកប្រាក់ដើមមុនកាលកំណត់

៣.១ អតិថិជនអាចបញ្ចប់កិច្ចសន្យាប្រាក់បញ្ញើមុនកាលកំណត់បាន លុះត្រាតែមានការយល់ព្រមពីធនាគារ អេស៊ីលីដា ភីអិលស៊ី ជាមុនសិន ។

៣.១.១ អតិថិជនជាគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ៖

៣.១.១.១ គណនីមានកាលកំណត់កំណើនខ្ពស់ (Hi-Growth Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវជូនដំណឹងមុន យ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ មកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការដាក់ពាក្យស្នើសុំបញ្ចប់ ដើម្បីរាយការណ៍ជូនធនាគារជាតិ នៃ កម្ពុជា ឲ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។
- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- មិនផ្តល់ការប្រាក់ជូនអតិថិជនជាគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

៣.១.១.២ គណនីមានកាលកំណត់ចំណូលខ្ពស់ (Hi-Income Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវជូនដំណឹងមុន យ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ មកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការដាក់ពាក្យស្នើសុំបញ្ចប់ ដើម្បីរាយការណ៍ជូនធនាគារជាតិ នៃ កម្ពុជា ឲ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។
- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- មិនផ្តល់ការប្រាក់ជូនអតិថិជនជាគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ ប្រសិនបើក្នុងអំឡុងពេលកន្លងមក អតិថិជនបានទទួលការប្រាក់ប្រចាំខែ ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដា ភីអិលស៊ី វិញ ។

៣.១.១.៣ គណនីមានកាលកំណត់រយៈពេលវែង (Long Term Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវជូនដំណឹងមុន យ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ មកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការដាក់ពាក្យស្នើសុំបញ្ចប់ ដើម្បីរាយការណ៍ជូនធនាគារជាតិ នៃ កម្ពុជា ឲ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។
- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- មិនផ្តល់ការប្រាក់ជូនអតិថិជនជាគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ ប្រសិនបើក្នុងអំឡុងពេលកន្លងមក អតិថិជនបានទទួលការប្រាក់ប្រចាំត្រីមាស ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដា ភីអិលស៊ី វិញ ។

៣.១.២ អតិថិជនជាឯកត្តជន ឬក្រុមហ៊ុន/អង្គភាព ក្រៅពីគ្រឹះស្ថានធនាគារ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ៖

៣.១.២.១ គណនីមានកាលកំណត់កំណើនខ្ពស់ (Hi-Growth Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- ផ្តល់ការប្រាក់ជូនអតិថិជន តាមអត្រាការប្រាក់នៃគណនីបញ្ញើសំចៃធម្មតា ។

៣.១.២.២ គណនីមានកាលកំណត់ចំណូលខ្ពស់ (Hi-Income Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- ផ្តល់ការប្រាក់ជូនអតិថិជន តាមអត្រាការប្រាក់នៃគណនីបញ្ញើសំចៃធម្មតា ។ ប្រសិនបើក្នុងអំឡុងពេលកន្លងមក អតិថិជនបានទទួលការប្រាក់ប្រចាំខែ ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើម ដើម្បីទូទាត់សងមកធនាគារ អេស៊ីលីដា ភីអិលស៊ី វិញ ។

៣.១.២.៣ គណនីមានកាលកំណត់រយៈពេលវែង (Long Term Fixed Deposit) ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវជូនដំណឹងមុន យ៉ាងតិច ៣០ថ្ងៃនៃថ្ងៃធ្វើការ មកធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈការដាក់ពាក្យស្នើសុំបញ្ចប់ ដើម្បីរាយការណ៍ជូនធនាគារជាតិ នៃ កម្ពុជា ឲ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។
- ត្រូវភ្ជាប់មកនូវវិញ្ញាបនបត្រប្រាក់បញ្ញើ នៃគណនីមានកាលកំណត់ដែលស្នើសុំដកប្រាក់ដើមមុនកាលកំណត់ ។
- ផ្តល់ការប្រាក់ជូនអតិថិជន តាមអត្រាការប្រាក់នៃគណនីបញ្ញើសំចៃធម្មតា ក្នុងករណីអតិថិជនជូនដំណឹងដូចខាងលើ បើមិនដូច្នោះទេការប្រាក់មិនត្រូវបានផ្តល់ជូនឡើយ ។ ប្រសិនបើក្នុងអំឡុងពេលកន្លងមក អតិថិជនបានទទួលការប្រាក់ប្រចាំត្រីមាស ត្រូវកាត់កងការប្រាក់ជាមួយប្រាក់ដើមត្រលប់មកវិញ តាមនីតិវិធីមានស្រាប់ ។

៤- ចំណូលការប្រាក់របស់អតិថិជនត្រូវជាប់ពន្ធស្របតាមប្រកាស ស្តីពីពន្ធលើប្រាក់ចំណេញរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៥- ការបន្តកិច្ចសន្យាស្វ័យប្រវត្តិ កើតឡើងនៅពេលដែលអតិថិជនបានស្នើសុំដាក់ប្រាក់បញ្ញើបន្តមួយវគ្គទៀត ឬច្រើនវគ្គបន្តបន្ទាប់គ្នាដោយមិនមានការផ្លាស់ប្តូរលេខកិច្ចសន្យាថ្មី ។ ការបន្តបែបនេះ គឺអាស្រ័យទៅតាមការបង្គាប់របស់អតិថិជនតាមរយៈការផ្តល់ព័ត៌មាននៅពេលបើកគណនី ឬជូនដំណឹងនៅពេលណាមួយក្នុងអំឡុងពេលនៃកិច្ចសន្យា ឬយ៉ាងតិចបំផុតពីរថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃបញ្ចប់កិច្ចសន្យា ។

៦- នៅពេលអតិថិជនជ្រើសរើសលក្ខខណ្ឌបន្តដោយស្វ័យប្រវត្តិ មានន័យថា អតិថិជនព្រមព្រៀងបន្តផ្ញើប្រាក់ជាមួយធនាគារតទៅទៀត ដែលមានប្រាក់ដើម ឬប្រាក់ដើមរួមទាំងការប្រាក់ដែលបានទទួល និងរយៈពេលផ្ញើនៅរក្សាដូចកិច្ចសន្យាដែលបានព្រមព្រៀងពីដំបូងដដែល លើកលែងតែអត្រាការប្រាក់ត្រូវអនុវត្តដូចខាងក្រោម ៖

- គិតជូនអតិថិជនតាមអត្រាការប្រាក់ធម្មតាដែលធនាគារ អេស៊ីលីដា ភីអិលស៊ី ដាក់ឲ្យប្រើប្រាស់ជាផ្លូវការចុងក្រោយបង្អស់ ។
- ចំពោះអតិថិជនដែលមានកិច្ចព្រមព្រៀងផ្តល់អត្រាការប្រាក់ពិសេស មិនអនុញ្ញាតឲ្យជ្រើសរើសលក្ខខណ្ឌបន្តជាស្វ័យប្រវត្តិឡើយ ។ ករណីមានតម្រូវការដាក់ប្រាក់បញ្ញើបន្តទៀត គឺត្រូវគិតការប្រាក់តាមអត្រាធម្មតាវិញ ។

៧- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសិទ្ធិពេញលេញក្នុងការបដិសេធ មិនទទួល ឬមិនបន្តកិច្ចសន្យា ឬបញ្ឈប់កិច្ចសន្យា មុនពេលកំណត់ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនដោយគ្មានបញ្ជាក់ពីមូលហេតុឡើយ ។

៨- ករណីអតិថិជនស្នើសុំវិញ្ញាបនបត្រប្រាក់បញ្ញើថ្មី ជំនួសវិញ្ញាបនបត្រប្រាក់បញ្ញើចាស់ដែលបានបាត់ ឬខូច អតិថិជនត្រូវបង់ថ្លៃសេវាតាមការកំណត់របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

<u>សម្គាល់៖</u> សម្រាប់តម្រូវការប្រើប្រាស់សេវាធនាគារ និងព័ត៌មានផ្សេងៗទៀត សូមទាក់ទងការិយាល័យទំនាក់ទំនងអតិថិជន ២៤ម៉ោង តាមរយៈទូរស័ព្ទលេខ : ០២៣ ៩៩៤ ៤៤៤/០១៥ ៩៩៩ ២៣៣ ឬ E-mail: inquiry@acledabank.com.kh ។

ខ្ញុំ/យើងខ្ញុំឈ្មោះ.................................... ជាអតិថិជនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអានយល់ និងព្រមព្រៀងគ្រប់ខចែង ដែលមានរៀបរាប់នៅក្នុងលក្ខខណ្ឌទូទៅខាងលើ ។

កាលបរិច្ឆេទ : ថ្ងៃទី......... ខែ......... ឆ្នាំ..........

ហត្ថលេខា/ស្នាមមេដៃ